# ឆ្មបជាអ្នកដឹកនាំក្នុងការផ្ដល់សេវា សុខភាពមាតា និងទារកមានគុណភាព

បង្ហាញដោយ **ឈិន សុខណាយ** ប្រធានសមាគមឆ្មបកម្ពុជា

ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២៦

សណ្ឋាគារ កាំបូឌីយ៉ាណា



*ទិវាឆ្មបជាតិ-អន្តរជាតិ ៥ ឧសភា*

# មាតិកា

- សេចក្តីផ្តើម
- អ្នកដឹកនាំថែទាំសុខភាព
- សមត្ថភាពស្នូលរបស់ឆ្មប
- ស្ថានភាពនៃការថែទាំ
- តួនាទីរបស់ឆ្មប
- ពង្រឹងសមត្ថភាព និងបង្កើនចំនួនឆ្មប
- តម្រូវការក្នុងការកែលម្អ
- គោលការណ៍ណែនាំសម្រាប់ការប្រកបវិជ្ជាជីវៈឆ្មប



# សេចក្តីផ្តើម

- ប្រទេសកម្ពុជាបានធ្វើឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់នៅក្នុងវិស័យឆ្មប ដោយបង្កើនកម្លាំងឆ្មបទ្វេដងរវាងឆ្នាំ២០១០ និង២០២៣។
- ប្រទេសកម្ពុជាបានអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល មានគោលបំណងការពារសុខភាព និងសុវត្ថិភាពសាធារណៈជន ដើម្បីធានាថាអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលមានគុណវុឌ្ឍិគ្រប់គ្រាន់ មានសមត្ថភាព  និងអនុវត្តប្រកបដោយសុវត្ថិភាព។
- ប្រព័ន្ធសុខាភិបាលកម្ពុជានៅតែជួបបញ្ហាកង្វះធនធានមនុស្ស។
- នៅមណ្ឌលសុខភាពខ្វះឆ្មបសរុបចំនួន ៥០៤នាក់។
-

(ការអភិវឌ្ឍន៍ធនធានមនុស្សសុខាភិបាល ២០២៥-២០៣៤)



# អ្នកដឹកនាំថែទាំសុខភាព

- ភាពជាអ្នកដឹកនាំការថែទាំ គឺជាទិដ្ឋភាពដ៏សំខាន់នៃការថែទាំសុខភាពដោយមានចូលរួមពីអ្នកថែទាំ ក្នុងការអនុវត្តតួនាទីដែលមានឥទ្ធិពលដឹកនាំសហការី និងទិសដៅនៃគោលនយោបាយថែទាំសុខភាព។
- ការដឹកនាំ និងការគ្រប់គ្រងត្រូវមានការចូលរួមលើកកម្ពស់ថែទាំអ្នកជំងឺ ជាដំណើរការរដ្ឋាបាល និងប្រព័ន្ធផ្តល់សេវាសុខាភិបាល។
- អ្នកដឹកនាំដែលទទួលបានជោគជ័យ គឺជាអ្នកដែលរៀបចំឱ្យអ្នកដទៃចូលរួមធ្វើការងាររួមគ្នាប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវគោលដៅរួម។
- អ្នកដឹកនាំមានតួនាទី៖ ធ្វើផែនការយុទ្ធសាស្ត្រ និងសម្រេចចិត្ត គ្រប់គ្រងប្រកបដោយប្រសិទ្ធភាព គាំទ្រដល់ការអភិវឌ្ឍ ចូលរួមកែលម្អគុណភាពថែទាំ គាំទ្រមតិ និងសហការប្រាស្រ័យទាក់ទងវិជ្ជាជីវៈ

ការគ្រប់គ្រងការថែទាំនិងភាពជាអ្នកដឹកនាំ
នាយកដ្ឋានធនធានមនុស្ស ខែមេសា ឆ្នាំ២០២៥



# បរិបទនៃការថែទាំដោយឆ្មប

- ឆ្មបត្រូវបានគេទទួលស្គាល់ថា ជាអ្នកប្រកបវិជ្ជាជីវៈដែលមានទំនួលខុសត្រូវ និងគណនេយ្យភាព ដែលធ្វើការក្នុងភាពជាដៃគូជាមួយស្ត្រីដើម្បីផ្តល់ការគាំទ្រ ការថែទាំ និងដំបូន្មានដែលចាំបាច់ក្នុងអំឡុង ពេលមានផ្ទៃពោះ ការឈឺពោះ ការសម្រាល និងពេលក្រោយសម្រាល ធ្វើការសម្រាលកូនក្រោមការទទួល ខុសត្រូវផ្ទាល់របស់ឆ្មប និងផ្តល់ការថែទាំដល់ទារកទើបនឹងកើត។
- ការថែទាំនេះ រួមមានវិធានការបង្ការ ការលើកកម្ពស់ការសម្រាលតាមធម្មតា ការស្រាវជ្រាវរកផលវិបាករបស់ មាតា និងទារក ការទទួលបានការថែទាំសុខភាព ឬជំនួយសមរម្យផ្សេងទៀតប្រសិនបើត្រូវការ និងការអនុវត្តវិធានការ សង្គ្រោះបន្ទាន់ ឆ្មបមានតួនាទីសំខាន់ក្នុងការផ្តល់ប្រឹក្សា និងអប់រំសុខភាព មិនត្រឹមតែសម្រាប់ស្ត្រី ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងគ្រួសារ និងសហគមន៍ផងដែរ។

ដែនកំណត់វិជ្ជាជីវៈឆ្មប ខែកញ្ញា ឆ្នាំ២០២២



# សមត្ថភាពស្នូលរបស់ឆ្មប

១ • សមត្ថភាពផ្នែកសង្គម អេពីដមីសាស្ត្រ បរិបទវប្បធម៌ និងបរិដ្ឋាន

២ • សមត្ថភាពថែទាំមុនពេលមានផ្ទៃពោះ និងពន្យារកំណើត

៣ • សមត្ថភាពថែទាំមុនពេលមានផ្ទៃពោះ

៤ • សមត្ថភាពថែទាំអំឡុងពេលឈឺពោះសម្រាល និងសម្រាល

៥ • សមត្ថភាពថែទាំក្រោយពេលសម្រាល

៦ • សមត្ថភាពថែទាំទារកទើបនឹងកើត

៧ • សមត្ថភាពផ្នែកសម្របសម្រួលលើការរំលូត

៨ • សមត្ថភាពផ្នែកឥរិយាបទវិជ្ជាជីវៈ និងបុគ្គល


ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

ប្រកាស

ស្តីពី

ក្របខណ្ឌសមត្ថភាពស្នូលសម្រាប់វិជ្ជាជីវៈឆ្មប

ពេលបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ

នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ខែ តុលា ឆ្នាំ ២០២២ ក្រសួងសុខាភិបាល



# ស្ថានភាពនៃការថែទាំ



120%
100%
80%
60%
40%
20%
0%
39%
23%
69%
49%
79%
79%
95%
93%
99%
99%
CDHS 2000
CDHS 2005
CDHS 2010
CDHS 2014
CDHS 2021-22
ANC
DV




# ស្ថានភាពនៃការថែទាំ




MPDSR Report, 2025



# ស្ថានភាពនៃការថែទាំ




សមិទ្ធផលវិស័យសុខាភិបាល ឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦



# ស្ថានភាពនៃការថែទាំ




របាយការណ៍សមិទ្ធផលសុខាភិបាលឆ្នាំ២០២៥ និងទិសដៅឆ្នាំ២០២៦



# តួនាទីរបស់ឆ្មប

- ភាពជាដៃគូជាមួយស្ត្រីដើម្បីលើកកម្ពស់ការថែទាំ សុខភាពរបស់មាតា ទារក ដោយក្រុម គ្រួសារ និង
- ស្ត្រីខ្លួនឯង។
- ការគោរពដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងស្ត្រី ជាមនុស្សដែលមានការគោរពសិទ្ធិមនុស្សពេញលេញ។
- ការលើកកម្ពស់សមភាពយេនឌ័រ និងស្វែងរកការគាំទ្រក្នុងនាមស្ត្រី ដើម្បីឱ្យសំឡេងរបស់ពួកគេត្រូវ បានគេទទួលស្គាល់។
- ការយកចិត្តទុកដាក់ដល់វប្បធម៌ រួមទាំងការធ្វើការជាមួយស្ត្រី និងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដទ ទៀត ដើម្បីជំនះអំពើហឹង្សាពាក់ព័ន្ធនឹងយេនឌ័រ និងការប្រព្រឹត្ត ផ្នែកវប្បធម៌នានាដែលបង្កគ្រោះថ្នាក់ ដល់ស្ត្រី ទារក និងកុមារ។
- ផ្តោតលើការលើកកម្ពស់សុខភាពនិងការបង្ការជំងឺដែលចាត់ទុកការមានផ្ទៃពោះជាព្រឹត្តិការណ៍ជីវិតធម្មតា។

ដែនកំណត់វិជ្ជាជីវៈឆ្មប ខែកញ្ញា ឆ្នាំ២០២២



# តួនាទីរបស់ឆ្មប

- ជាសិល្បៈ និងវិទ្យាសាស្ត្រនៃការថែទាំ ដែលត្រូវបានសម្គាល់ដោយការគិត ពិចារណា ការអនុវត្តបែបឆ្លុះបញ្ចាំង និងរួមមានការថែទាំដែលផ្តល់ជូនតាមរយៈការអនុវត្តដោយស្វ័យភាព។
- ជាជីវៈមួយដែលផ្អែកលើគោលការណ៍ច្បាប់ និងក្រមសីលធម៌ និងរួមបញ្ចូលការបង្ហាញពីភាពជាអ្នកដឹកនាំ ការបង្ហាត់បង្ហាញ ការអភិបាល ការស្វែងរកការគាំទ្រ ការស្រាវជ្រាវ ការបណ្តុះបណ្តាល ការគ្រប់គ្រង ការចូលរួមក្នុងការអភិវឌ្ឍគោលនយោបាយ និងការលើកកម្ពស់សុវត្ថិភាព បរិស្ថាន សម្រាប់ការផ្តល់ការថែទាំដោយឆ្មប។
- ឆ្មបមានតួនាទីអភិវឌ្ឍ និងផ្តល់ការថែទាំ ផ្តោតលើអតិថិជន ដោយប្រើរបៀបនៃការថែទាំឆ្មប ដោយ ប្រកាន់ខ្ជាប់តាមនិយាមនៃការអនុវត្ត និងក្រមសីលធម៌វិជ្ជាជីវៈឆ្មប ។
- អតិថិជន ទទួលខុសត្រូវចំពោះសុខភាពផ្ទាល់ខ្លួនរបស់ពួកគេ និងត្រូវបានគោរពដោយ ឆ្មបជាដៃគូ ក្នុងការផ្តល់សេវាថែទាំ។

ដែនកំណត់វិជ្ជាជីវៈឆ្មប ខែកញ្ញា ឆ្នាំ២០២២



# ពង្រឹងសមត្ថភាព និងបង្កើនចំនួនឆ្មប

១) ការបណ្តុះបណ្តាលមុនពេលបម្រើការងារ

- ពិនិត្យមើលភាពស្របគ្នានៃការអប់រំមុនចូលបម្រើការងារ
- បង្កើត និងអនុវត្តកម្មិធីសម្រាបើគ្រូបង្រៀន ពង្រឹងសមត្ថភាពគ្រូតាមកម្មវិធីបណ្តុះបណ្តាលក្នុងពេលបំពេញការងារ
- ធ្វើបច្ចុប្បន្នភាពសម្ភារបង្រៀន និងកម្មវិធីសិក្សា

២) ចំនួនឆ្មបដែលមានស្រាប់

- អនុវត្តផែណការសុខាភិបាលធនធានមនុស្សឆ្នាំ២០២៤-២០២៣៣
- ជ្រើសរើសឆ្មប ៣០០នាក់ ក្នុង១ឆ្នាំ ដើម្បីបំពេញតម្រូវការ មណ្ឌលសុខភាព២១៦កន្លែង មានឆ្មបតែម្នាក់
- ឆ្មបចុះកិច្ចសន្យាឆ្មបផ្តល់អទិភាព ឬដល់ឱកាសឆ្មននៅនឹងមូលដ្ឋានសុខាភិបាល

ផែនទីបង្ហាញផ្លូវ សម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក ឆ្នាំ២០២៥-២០៣០



# ពង្រឹងសមត្ថភាព និងបង្កើនចំនួនឆ្មប

៣) បទបញ្ញត្តិ និងការផ្តល់អាជ្ញាបណ្ណ

- ត្រួតពិនិត្យរចនាសម្ព័ន្ធនៃគណៈឆ្មប នៅថ្នាក់កណ្តាល និងស្វែងរកមតិគាំទ្រ ឬប្រមូលផ្តុំធនធានបន្ថែមទៀត
- ធ្វើបច្ចុប្បន្នភាពដើម្បីធានាបាននូវការគាំទ្រផ្នែកច្បាប់ និងការការពារសម្រាប់ឆ្មប ដើម្បីផ្តល់សេវាសំខាន់ៗប្រកបដោយគុណភាព។
- បន្តចុះបញ្ជិកា និងផ្តល់អាជ្ញាបណ្ណឆ្មប ស្របតាមស្តង់ដាអប្បបរមាសម្រាប់ការបន្តវិជ្ជាជីវៈឆ្មប

៤) បណ្តុះបណ្តាលក្នុងពេលបម្រើការងារ៖ បង្កើនគុណភាព និងត្រូវតាមកាលវិភាគនៃការថែទាំមុនពេលសម្រាល ពេលសម្រាល និងក្រោយសម្រាល

- បន្តការបង្រឹកនៅនឹងកន្លែង
- វាយតម្លៃតម្រូវការ និងបណ្តុះបណ្តាល EmONC
- បណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងភាពជាអ្នកដឹកនាំសម្រាប់ឆ្មប
- អនុវត្តការកែលម្អគុណភាពនៅនឹងកន្លែង ស្របតាមគោលការណ៍ណែនាំជាតិ ការថែទាំមុនសម្រាល សម្រាល និងក្រោយសម្រាល។

# ពង្រឹងសមត្ថភាព និងបង្កើនចំនួនឆ្មប

សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើត (EmONC) និងការពិនិត្យមរណភាពមាតា និងទារក និងការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប (MPDSR)

- ខណៈពេលដែលការមានផ្ទៃពោះ និងសម្រាលកូន ប្រហែល១៥% នៃស្ត្រីបានវិវត្តន៍ទៅលក្ខខណ្ឌគំរាមកំហែងដល់ជីវិត។
- កែលម្អការគ្រប់ដណ្តប់សេវាសង្គ្រោះបន្ទាន់
- ពង្រឹងប្រព័ន្ធបញ្ជូន
- ការពិគ្រោះពីចម្ងាយ

ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក ឆ្នាំ២០២៥-២០៣០



# តម្រូវការក្នុងការកែលម្អ

តាមរយៈការពិនិត្យមរណភាពមាតា និងទារក និងការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការឆ្លើយតប (MPDSR) បានបង្ហាញថា នៅមានបញ្ហាប្រឈម៖

- កំណត់ចំណាត់ថ្នាក់ហានិភ័យ
- ការតត់ត្រា និងរាយការណ៍ពីមូលហេតុនៃមរណភាព
- ការផ្តល់ព័ត៌មានត្រឡប់ទៅថ្នាក់ខេត្តយឺតយ៉ាវ
- មិនមានទិន្នន័យអំពីលទ្ធផល

ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក ឆ្នាំ២០២៥-២០៣០



# តម្រូវការក្នុងការកែលម្អ

គុណភាព និងការគ្រប់ដណ្តប់ នៃការថែទាំទារកជាសារវន្ត ទារកទើបនឹងកើត (ការថែទាំនិងការថែទាំទារកដែលមានតម្រូវការពិសេស៖

- ខណៈពេលស្ត្រីសម្រាលចំនួន ៩៧.៨% នៅមូលដ្ឋានសុខាភិបាល មាន៧៦.៨% បានដាក់ទារកលើទ្រូងម្តាយ
- ម្តាយ និងទារក ៧៥.៣% ទទួលបានការថែទាំក្រោយសម្រាល
- ម្តាយ ៥២.៦% ប៉ុណ្ណោះបានទទួលការពិគ្រោះពីការបំបៅដោះម្តាយ និងសង្កេតមើលការបំបៅដោះ

**ការអនុវត្តនៅកម្រិតទាបនេះបាននាំឱ្យមានការថយចុះនៃការចាប់ផ្តើមបំបៅកូនដោយទឹកដោះម្តាយភ្លាម និងការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់**

ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក ឆ្នាំ២០២៥-២០៣០



# គោលការណ៍ណែនាំសម្រាប់ការប្រកបវិជ្ជាជីវៈឆ្មប

<u>ការថែទាំប្រកបដោយគុណភាព</u>៖ ឆ្មបដែលបានចុះបញ្ជិកា និងមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ អនុវត្តវិធីសាស្រ្តកែលម្អគុណភាពនៅក្នុងការផ្តល់សេវា

<u>ការអភិវឌ្ឍវិជ្ជាជីវៈបន្ត</u>៖ រៀនសូត្រជាបន្តពេញមួយជីវិត ធ្វើការបង្រីកនូវចំណេះដឹង និងធ្វើបច្ចុប្បន្នភាពជំនាញ

អនុវត្តផ្អែកលើភ័ស្តុតាង៖ ប្រើប្រាស់ការគិត និងពិចារណា ការខ្លះបញ្ចាំង ការសាកសួរ និងទិន្នន័យពីការស្រាវជ្រាវនៅពេលធ្វើការសម្រេចចិត្តថែទាំ ផ្អែកលើភ័ស្តុតាងដែលមាន។

<u>ស្វ័យភាពវិជ្ជាជីវៈ</u>៖ មានសមត្ថភាពសម្រេចចិត្តថែទាំ ។និងឥស្សរភាពក្នុងការផ្តល់សេវា យោងតាមចំណេះដឹង មត្តភាពជំនាញ សិទ្ធិអំណាចផ្លូវច្បាប់ និងដែនកំណត់នៃការអនុវត្ត។

<u>គាំទ្រអាតិថិជន</u>៖ ស្វែងរកការគាំទ្រ ផ្តល់សេវាថែទាំប្រកបដោយសមធម៌ បរិយាកាសថែទាំសុខភាពប្រកបដោយសុវត្ថិភាព និងផ្តល់សេវាប្រកបដោយគុណភាព។

ដែនកំណត់វិជ្ជាជីវៈឆ្មប ខែកញ្ញា ឆ្នាំ២០២២

# Thank You

